# ព្រះពុទ្ធសាសនា សាសនាអ៊ិស្លាម និងពហុសាសនានៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍

*ពុទ្ធបរិស័ទនៅប្រទេសថៃ កម្ពុជា និងស្រីលង្កាមើលឃើញថាមានការផ្សារភ្ជាប់គ្នាយ៉ាងរឹងមាំរវាងសាសនា និងប្រទេសរបស់ពួកគេ ដូចជាជនជាតិម៉ូស្លីមនៅក្នុងប្រទេសម៉ាឡេស៊ី និងឥណ្ឌូណេស៊ី។*

នៅក្នុងប្រទេសកម្ពុជា ស្រីលង្កា និងប្រទេសថៃ ដែលជាប្រទេស ដែលមានមនុស្សពេញវ័យយ៉ាងតិច 70% ជាពុទ្ធបរិស័ទ– **លើស ពីប្រាំបួននាក់ក្នុងចំណោមដប់នាក់និយាយថា ការធ្វើជាពុទ្ធបរិស័ទមានសារៈសំខាន់ក្នុង ការក្លាយជាផ្នែកមួយនៃប្រជាជាតិរបស់ពួកគេ** នេះបើយោងតាមការស្ទង់មតិរបស់ Pew Research Center ទៅលើប្រទេសទាំងប្រាំមួយនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍។

ឧទាហរណ៍ 95% នៃពុទ្ធបរិស័ទនៅប្រទេសស្រីលង្កា និយាយថា ការក្លាយជាពុទ្ធបរិស័ទ គឺមានសារៈសំខាន់ ដើម្បីក្លាយជាប្រជាជនស្រីលង្កាពិតប្រាកដ ហើយមាន 87% ដែលនិយាយថា ព្រះពុទ្ធសាសនាមានសារៈសំខាន់ *ខ្លាំងណាស់* ដើម្បីធ្វើជាប្រជាជនស្រីលង្កាពិតប្រាកដ។ ទោះបីជាប្រជាជននៅក្នុងប្រទេសទាំងនេះ ភាគច្រើនកំណត់ខ្លួនថា ជាពុទ្ធបរិស័ទក៏ដោយ **ក៏មានការយល់ស្របយ៉ាងទូលំទូលាយថា**

## អំពីការស្ទង់មតិ

គោលដៅសំខាន់អំពីការស្ទង់មតិនេះ គឺដើម្បីស្វែងយល់អំពីសាសនា និងព្រះពុទ្ធសាសនា ជាពិសេសនៅអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍។

យើងបានធ្វើការស្ទង់មតិមនុស្សពេញវ័យចំនួន 13,122 នាក់នៅទូទាំងប្រទេសចំនួនប្រាំមួយ រួមមាន៖

- កម្ពុជា
- ម៉ាឡេស៊ី
- ឥណ្ឌូណេស៊ី
- សិង្ហបុរី
- ស្រីលង្កា
- ថៃ

ការស្ទង់មតិនេះ រួមមានប្រទេសចំនួនបី ដែលភាគច្រើនបំផុតជាពុទ្ធបរិស័ទ (កម្ពុជា ស្រីលង្កា និងថៃ)។ ប្រទេសពីរទៀត ដែល មានប្រជាជនម៉ូស្លីមភាគច្រើន (ម៉ាឡេស៊ី និងឥណ្ឌូណេស៊ី)។ និងប្រទេសមួយទៀតដែលមានសាសនាចម្រុះ ដោយគ្មាន ក្រុមណាមួយបង្កើតបានជាក្រុមភាគច្រើនបំផុតទេ (សិង្ហបុរី)។

របាយការណ៍ពេញលេញមានរួមបញ្ចូលរបបគំឃើញអំពីក ម្រិតខុសគ្នានៃជំនឿសាសនាតាមអាយុ ការអនុវត្តពិធីបុណ្យសព អាទិទេព និងមានច្រើនទៀត។

## ព្រះពុទ្ធសាសនាគឺមិនត្រឹមជាសាសនាតែប៉ុណ្ណោះទេ។

អ្នកស្រាវជ្រាវជាន់ខ្ពស់ ចូណាថាន់ អ៊ីវ៉ាន បាននិយាយថា “សម្រាប់មនុស្សភាគច្រើននៅក្នុងបណ្តាប្រទេសអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ដែលយើងបានស្ទង់មតិ អត្តសញ្ញាណសាសនា គឺមានអត្ថន័យលើសពីជំនឿ និងការប្រតិបត្តិ - អត្តសញ្ញាណ សាសនាក៏និយាយអំពីវប្បធម៌ ប្រពៃណីគ្រួសារ និងជនជាតិដើមផងដែរ។” “យើងក៏បានរកឃើញផងដែរថា មនុស្សជាច្រើនបានចងភ្ជាប់សាសនាណាមួយយ៉ាងខ្លាំងទៅនឹងអត្តសញ្ញាណជាតិ។ ប៉ុន្តែទោះបីជាមនុស្សបង្ហាញគំនិតយោបល់ទូទៅអំពីនៃការអត់ឱន និងចុះសម្រុងខាងសាសនា។”

## ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជា ស្រីលង្កា និងថៃ

សារៈសំខាន់នៃព្រះពុទ្ធសាសនាក្នុងអត្តសញ្ញាណជាតិត្រូវបានឆ្លុះបញ្ចាំងនៅក្នុងភាពលេចធ្លោនៃច្បាប់របស់ប្រទេសទាំងបីនេះដែលផ្អែកលើព្រះពុទ្ធសាសនា។ ដោយផ្អែកតាមការស្ទង់មតិនេះ **ពុទ្ធបរិស័ទភាគច្រើននៅក្នុងប្រទេសទាំងបី ពេញចិត្តនឹងច្បាប់ជាតិរបស់ខ្លួន ដែលមានមូលដ្ឋានលើធម៌ព្រះពុទ្ធសាសនា** – ដែលជាគោលគំនិតទូលំទូលាយ ដែលរួមបញ្ចូលចំណេះដឹង លទ្ធិ និងការអនុវត្តដែលកើតចេញពីការបង្រៀនរបស់ព្រះពុទ្ធ។ ទស្សនៈនេះ គឺមានស្ទើរតែជាឯកច្ឆន្ទទៅហើយនៅក្នុងចំណោមពុទ្ធបរិស័ទខ្មែរ (96%) ខណៈដែលពុទ្ធបរិស័ទភាគច្រើននៅស្រីលង្កា (80%) និងថៃ (56%) និយមច្បាប់ជាតិដោយផ្អែកលើការបង្រៀន និងការអនុវត្តតាមព្រះពុទ្ធសាសនា។

**នៅពេលសួរអំពីតួនាទី របស់មេដឹកនាំសាសនាក្នុងជីវិតសាធារណៈ ពុទ្ធបរិស័ទជនជាតិខ្មែរបង្ហាញលេចធ្លោរជាងគេថា ទំនងជាពេញចិត្តជាងគេទៅលើទំនាក់ទំនងរវាងសាសនានិងរដ្ឋាភិបាល។** ឧទាហរណ៍ 81% នៃពុទ្ធបរិស័ទជនជាតិខ្មែរ និយាយថា មេដឹកនាំសាសនាគួរតែបោះឆ្នោតក្នុងការបោះឆ្នោតនយោបាយ ដែលការប្រកាន់ជំហរបែបនេះ គឺមានសមាមាត្រតូចទេ សម្រាប់ពុទ្ធបរិស័ទនៅស្រីលង្កា (66%) និងថៃ (54%) ។ ប៉ុន្តែនៅកម្ពុជា បើទោះមានការគាំទ្រស្ទើរតែជាឯកច្ឆន្ទលើច្បាប់ដោយផ្អែកលើធម៌របស់ព្រះពុទ្ធសាសនាក៏ដោយ ពុទ្ធបរិស័ទជនជាតិខ្មែរមិនលើសពីពាក់កណ្តាលទេ និយាយថា មេដឹកនាំសាសនាគួរតែចូលរួមក្នុងការតវ៉ានយោបាយ (50%) និយាយជាសាធារណៈអំពីអ្នកនយោបាយដែលពួកគេគាំទ្រ (47%) ឬ ធ្វើជាអ្នកនយោបាយខ្លួនឯងផ្ទាល់ (45%)។

## សាសនាឥស្លាមនៅប្រទេសម៉ាឡេស៊ី និងឥណ្ឌូណេស៊ី

បើយើងក្រឡេកមើលទៅការភ្ជាប់ព្រះពុទ្ធសាសនាទៅនឹងអត្តសញ្ញាណជាតិនៅក្នុងប្រទេសទាំងនេះ គឺដូចគ្នាទៅនឹងតួនាទីរបស់សាសនាឥស្លាមនៅក្នុងប្រទេសជិតខាង ដែលមានជនមូស្លីមភាគច្រើន គឺប្រទេសឥណ្ឌូណេស៊ី និងម៉ាឡេស៊ី។ **ស្ទើរតែគ្រប់ជនជាតិមូស្លីមនៅក្នុងប្រទេសទាំងពីរនេះនិយាយថា ការក្លាយជាជនជាតិមូស្លីម គឺមានសារៈសំខាន់ ដើម្បីក្លាយជាជនជាតិឥណ្ឌូណេស៊ី ឬម៉ាឡេស៊ីពិតប្រាកដ។** ជនជាតិមូស្លីមក្នុងប្រទេសទាំងពីរតែងពណ៌នាអំពីសាសនាឥស្លាមថាជាវប្បធម៌ ប្រពៃណីគ្រួសារ ឬជនជាតិដើមហើយវាមិនមែនគ្រាន់តែជា «សាសនាមួយដែលគេជ្រើសរើសធ្វើតាមទេ»។ ឧទាហរណ៍ ជនជាតិមូស្លីមម៉ាឡេស៊ីចំនួនបីភាគបួននិយាយថា ឥស្លាម គឺជា «ជាជនជាតិដើមមួយដែលមនុស្សម្នាក់ៗបានចាប់កំណើតមក»។

ជនជាតិមូស្លីមភាគច្រើននៅក្នុងប្រទេសទាំងពីរពេញចិត្តនឹងការយកច្បាប់សារីអះធ្វើជាច្បាប់ផ្លូវការនៃប្រទេសនេះ។ ជនជាតិមូស្លីមនៅម៉ាឡេស៊ីកន្លែងដែលសាសនាអ៊ីស្លាម គឺជាសាសនាផ្លូវការ គាំទ្រយ៉ាងលើសលុបក្នុងការប្រើប្រាស់ច្បាប់សារីអះជាច្បាប់ជាតិ (86%)។ ការគាំទ្រសម្រាប់ច្បាប់សារីអះ គឺមានទាបជាងនេះបន្តិចក្នុងចំណោមជនជាតិមូស្លីមនៅក្នុងប្រទេសឥណ្ឌូណេស៊ី ដែល 64% នៃជនជាតិមូស្លីមឥណ្ឌូណេស៊ីនិយាយថា ច្បាប់សារីអះ គួរតែត្រូវបានប្រើប្រាស់ជាច្បាប់របស់ប្រទេសនេះ។

**ជនជាតិមូស្លីមទាំងនៅក្នុងប្រទេសឥណ្ឌូណេស៊ី និងម៉ាឡេស៊ី ទំនងជានឹងអាចពេញចិត្តនឹងតួនាទីដ៏ខ្ពង់ខ្ពស់ សម្រាប់មេដឹកនាំ សាសនាក្នុងផ្នែកនយោបាយ ជាងពុទ្ធបរិស័ទដែលត្រូវបានស្ទង់មតិនៅក្នុងប្រទេសជិតខាង។** ឧទាហរណ៍ ជនជាតិមូស្លីមភាគច្រើននៅក្នុងប្រទេសឥណ្ឌូណេស៊ី (58%) និងម៉ាឡេស៊ី (69%) និយាយថា មេដឹកនាំសាសនាគួរតែនិយាយជាសាធារណៈអំពីអ្នកនយោបាយ និងគណបក្សនយោបាយដែលខ្លួនគាំទ្រ។

## ពហុសាសនានៅប្រទេសសិង្ហបុរី

ការស្ទង់មតិក៏រួមបញ្ចូលប្រទេសសិង្ហបុរីដែរ ដែលមិនមានសាសនាណាធំជាងគេនោះទេ ហើយតាមការវាស់ស្ទង់មួយចំនួន គឺប្រទេសនេះជាសង្គមដែលមានសាសនាចម្រុះច្រើនបំផុតលើពិភពលោក។

ប្រជាជនសិង្ហបុរីភាគច្រើន (56%) និយាយថា ការដែលមានប្រជាជនមានសាសនា ក្រុមជនជាតិដើម និងវប្បធម៌ច្រើនចម្រុះគ្នា ធ្វើឱ្យប្រទេសរបស់ពួកគេក្លាយជាកន្លែងរស់នៅប្រសើរជាងមុន។ ខណៈដែលប្រជាជនសិង្ហបុរីតិចតួច (4%) និយាយថា វាធ្វើឱ្យប្រទេសរបស់ពួកគេក្លាយជាជាកន្លែងដ៏អាក្រក់បំផុតមួយសម្រាប់រស់នៅ។ **ហើយផ្អែកទៅលើការវាស់ស្ទង់ទៅលើការអត់ឱន និងចុះសម្រុងខាងសាសនា ប្រជាជនសិង្ហបុរីបង្ហាញពីការទទួលយកទស្សនៈយ៉ាងទូលំទូលាយចំពោះក្រុមផ្សេងៗទៀត។**មនុស្សពេញវ័យជិតប្រាំបួននាក់ក្នុងចំណោមដប់នាក់នៅក្នុងប្រទេសសិង្ហបុរីនិយាយថា គ្រិស្តសាសនា ឥស្លាម ហិណ្ឌូ និងសាសនាប្រពៃណីរបស់ចិន គឺមានភាពស៊ីសង្វាក់គ្នាជាមួយនឹងវប្បធម៌ និងគុណតម្លៃរបស់ប្រទេសសិង្ហបុរី។

## របបគំហើញបន្ថែម៖

- **ការអត់ឱន និងចុះសម្រុងខាងសាសនា៖** ជាទូទៅ ការអត់ឱន និងការចុះសម្រុងគ្នានៃសាសនាផ្សេងទៀតត្រូវបានផ្សាភ្ជាប់យ៉ាងទូលំទូលាយនៅក្នុងប្រទេសទាំងប្រាំមួយ។
    - មនុស្សពេញវ័យនៅក្នុងប្រទេសម៉ាឡេស៊ី និងស្រីលង្កា (ទាំងពីរប្រទេស 62%) គឺអាចនិយាយបានថា ភាពចម្រុះសាសនានៃជនជាតិ និងវប្បធម៌ គឺផ្តល់ផលប្រយោជន៍ដល់ប្រទេសរបស់ពួកគេ ច្រើនជាងប្រជាជននៅក្នុងប្រទេសសិង្ហបុរី (56%)។
    - នៅទូទាំងក្រុមសាសនាធំៗទាំងអស់ មនុស្សភាគច្រើននិយាយថា ពួកគេមានសេចក្តីសុខចិត្ត ក្នុងការទទួលយកសមាជិកនៃសហគមន៍សាសនាផ្សេងៗគ្នាធ្វើជាអ្នកជិតខាង។ ឧទាហរណ៍ 81% នៃពុទ្ធបរិស័ទនៅស្រីលង្កានិយាយថា ពួកគេសុខចិត្តមានអ្នកជិតជាហិណ្ឌូបរិស័ទ និងចំនួនស្រដៀងគ្នានេះដែរនៃហិណ្ឌូបរិស័ទនៅស្រីលង្កា (85%) និយាយយល់ស្របដូចគ្នាដែរអំពីពុទ្ធបរិស័ទ។

- **ជំនឿ និងការអនុវត្តរួម៖** មានសញ្ញានៃជំនឿ និងការអនុវត្តសាសនារួមគ្នាចម្រុះសាសនាផងដែរ។

 - ភាគច្រើននៃសហគមន៍សាសនាធំៗ ស្ទើរតែទាំងអស់ក្នុងប្រទេសទាំងប្រាំមួយនិយាយថា កម្មផល គឺមានពិត ទោះបីជា ជំនឿលើកម្មផលមិនត្រូវបានផ្សារភ្ជាប់តាមប្រពៃណីជាមួយនឹងក្រុមសាសនាទាំងអស់ដែលបានស្ទង់មតិនោះទេ។
 - មនុស្សជាច្រើនបន់ស្រន់ ឬថ្វាយការគោរពចំពោះអាទិទេព ឬរូបស្ថាបនិក ដែលមិនត្រូវបានចាត់ទុកថា ជាផ្នែកនៃព្រះនៃសាសនារបស់គេឡើយ។ ឧទាហរណ៍ 66% នៃហិណ្ឌូបរិស័ទនៅសិង្ហបូរី និយាយថា ពួកគេអធិស្ឋាន ឬថ្វាយការគោរពចំពោះព្រះយេស៊ូវគ្រីស្ទ ហើយ 62% នៃជនជាតិម៉ូស្លីមនៅស្រីលង្កាបួងសួងបន់ស្រន់ ឬថ្វាយការគោរពចំពោះអាទិទេពហិណ្ឌូព្រះគណេសដែរ។

- **ការផ្លាស់ប្តូរសាសនា៖** ទោះបីជាការបង្ហាញពីការអត់ឱនចុះសម្រុង និងការលាយបញ្ចូលគ្នានៃសាសនាក៏ដោយ អត្តសញ្ញាណសាសនាក៏អាចជាខ្សែបន្ទាត់ដ៏ច្បាស់រវាងក្រុមនីមួយៗ។ មនុស្សជាច្រើននៅប្រទេស ដែលបានស្ទង់មតិនិយាយថា វាមិនអាចទទួលយកបានទេក្នុងការដែលមនុស្សម្នាក់បោះបង់សាសនារបស់ខ្លួន ឬប្តូរទៅជំនឿផ្សេង។
  - នៅប្រទេសឥណ្ឌូណេស៊ី 92% នៃជនជាតិម៉ូស្លីមនិយាយថា វាមិនអាចទទួលយកបានទេក្នុងការដែលមនុស្សម្នាក់ចាកចេញពីសាសនាឥស្លាម ហើយ 83% នៃគ្រិស្តបរិស័ទនិយាយថា វាមិនអាចទទួលយកបានទេក្នុងការចាកចេញពីគ្រិស្តសាសនា ហើយទៅចូលសាសនាផ្សេង។ សរុបមក ជនជាតិម៉ូស្លីមទំនងជានឹងអាច ជាងសហគមន៍សាសនាផ្សេងទៀត ក្នុងការនិយាយថា ការប្រែចិត្តចេញពីជំនឿរបស់ពួកគេ គឺមិនអាចទទួលយកបានទេ។ ប៉ុន្តែនេះក៏ជាជំហររបស់ពុទ្ធបរិស័ទពីរភាគបី ឬច្រើនជាងនេះនៅក្នុងប្រទេសកម្ពុជា ស្រីលង្កា និងប្រទេសថៃ ដែលជាប្រទេសកាន់ពុទ្ធសាសនាភាគច្រើនចំនួនបីនៅក្នុងការសិក្សានេះ។
  - នៅក្នុងប្រាំប្រទេសក្នុងចំណោមប្រាំមួយ ដែលត្រូវបានស្ទង់មតិ មនុស្សពេញវ័យស្ទើរតែទាំងអស់នៅតែកំណត់អត្តសញ្ញាណខ្លួនជាមួយសាសនា ដែលពួកគេបានធំដឹងក្តីឡើងជាមួយ។ មានតែនៅក្នុងប្រទេសសិង្ហបុរីប៉ុណ្ណោះ ដែលមានបំណែកដ៏ធំនៃចំនួនមនុស្សពេញវ័យ (35%) ដែលបង្ហាញថា សាសនារបស់ពួកគេបានផ្លាស់ប្តូរក្នុងអំឡុងពេលជីវិតខ្លួនកន្លងមក។

ទាំងនេះស្ថិត គឺក្នុងចំណោមការរកឃើញសំខាន់ៗនៃការស្ទង់មតិរបស់ Pew Research Center ដែលធ្វើឡើងក្នុងចំណោមមនុស្សពេញវ័យ 13,122 នាក់ក្នុងប្រទេសចំនួន 6 នៅអាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង។

ការសម្ភាសត្រូវបានធ្វើឡើងដោយជួបមុខគ្នាផ្ទាល់ក្នុងប្រទេសកម្ពុជា ឥណ្ឌូណេស៊ី ស្រីលង្កា និងប្រទេសថៃ ហើយធ្វើឡើងតាមទូរសព្ទនៅម៉ាឡេស៊ី និងសិង្ហបុរី។ អ្នកសម្ភាសន៍ក្នុងតំបន់នីមួយៗបានអនុវត្តការស្ទង់មតិចាប់ពីខែមិថុនា រហូតដល់ខែកញ្ញា ឆ្នាំ 2022

ដែលប្រើភាសាចំនួនប្រាំបី។ កម្រិតល្មៀងនៃកំហុសសំណាកគំរូនៃប្រទេសនីមួយៗចន្លោះចាប់ពី 2.44 ដល់ 3.19 ភាគរយ។

របាយការណ៍នេះបានផលិតឡើងដោយ Pew Research Center ដែលជាផ្នែកមួយនៃគម្រោង Pew-Templeton Global Religious Futures projectដែលវិភាគពីការប្រែប្រួលនៃសាសនា និងឥទ្ធិពលនៃការប្រែប្រួលនេះទៅលើសង្គមជុំវិញពិភពលោក។ មូលនិធិសម្រាប់គម្រោងអនាគត Global Religious Futures បានមកពី The Pew Charitable Trusts និងមូលនិធិ John Templeton Foundation។

ដើម្បីអានរបាយការណ៍ពេញលេញជាភាសាអង់គ្លេស សូមចូលទៅកាន់៖ https://www.pewresearch.org/religion/2023/09/12/buddhism-islam-and-religious-pluralism-in-south-and-southeast-asia/%20

ទិដ្ឋភាពទូទៅនៃរបាយការណ៍នេះក៏មានជាភាសាហាឡ្មែរម: https://www.pewresearch.org/religion/wp-content/uploads/sites/7/2023/09/pr_2023.09.12_se-asia_khmer-overview.pdf

វិធីសាស្ត្រ (ជាភាសាអង់គ្លេស)៖ https://www.pewresearch.org/religion/2023/09/12/methodology-southeast-asia-2023/

សេចក្តីសង្ខេបអំពីរបបគំហើញសំខាន់ៗ (ជាភាសាអង់គ្លេស)៖ https://www.pewresearch.org/religion/wp-content/uploads/sites/7/2023/09/pr_2023.09.12_se-asia_topline.pdf

*សេចក្តីសង្ខេបនៃរបបគំហើញនេះត្រូវបានបកប្រែជាភាសា [បាហាសាឥណ្ឌូណេស៊ី ខ្មែរ ម៉ាឡេស៊ី ស៊ីនហាលិស ថៃ] ពីកំណែភាសាអង់គ្លេសដើមរបស់វា។*